# សិក្សាព្រះអភិធម្ម

មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ២

# បរមត្ថធម៌

ពាក្យថា បរមត្ថ មកពី បរម + អត្ថ = បរមត្ថ

បរម ប្រែថា ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត

អត្ថ ប្រែថា អត្ថ សេចក្ដី ឬន័យ

រួមពាក្យទាំងពីរចូលគ្នា បានជា បរមត្ថ ប្រែថា អត្ថ ឬសេចក្ដីដ៏ប្រសើរ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# បរមត្ថធម៌ មាន ៤ គឺ ៖

១- ចិត្តបរមត្ថ បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង

២- ចេតសិកបរមត្ថ បានដល់ ចេតសិក ៥២

៣- រូបបរមត្ថ បានដល់ រូប ២៨

៤- និព្វានបរមត្ថ បានដល់ ព្រះនិព្វាន

# ចេតសិកបរមត្ថ
## បរិច្ឆេទទី ២

ចេតសិក គឺជាធម៌ដែលកើតឡើងអាស្រ័យនឹងចិត្ត ឬថាជាធម៌ប្រកបជាមួយនឹងចិត្ត ប្រៀបដូចសិស្សនិងគ្រូ ដែលត្រូវអាស្រ័យគ្នា ទើបអាចញ៉ាំងថ្នាក់រៀនមួយឲ្យប្រព្រឹត្តទៅបាន។

ដូចមានវិគ្គហៈ ថា ៖

ចេតសិ ភវំ ចេតសិកំ វា ចេតសិ និយុត្តំ = ចេតសិកំ ធម្មជាតិកើត ក្នុងចិត្ត ឬប្រកបក្នុងចិត្ត ឈ្មោះថា ចេតសិក។

ចេតសិក មានអាការសម្គាល់ ៤ យ៉ាងគឺ ៖

១- ឯកុប្បាទៈ     កើតព្រមគ្នាជាមួយនឹងចិត្ត

២- ឯកនិរោធៈ    រលត់ព្រមគ្នាជាមួយនឹងចិត្ត

៣- ឯកាលម្ពណៈ មានអារម្មណ៍តែមួយជាមួយនឹងចិត្ត គឺថា ចិត្តដឹងអារម្មណ៍ណា ចេតសិកក៏ដឹងនូវអារម្មណ៍នោះ

៤- ឯកវត្ថុកៈ មានវត្ថុតែមួយដូចគ្នានឹងចិត្ត គឺថា ចិត្តអាស្រ័យវត្ថុណា ចេតសិកក៏អាស្រ័យវត្ថុនោះ (វត្ថុមាន ៦ គឺ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និង ហទយវត្ថុ)។

# លក្ខណាទិចតុក្កៈរបស់ ចេតសិក

| | |
|---|---|
| ១- ចិត្តនិស្សិតលក្ខណំ | មានការអាស្រ័យនឹងចិត្ត ជាលក្ខណៈ |
| ២- អវិយោគុប្បាទនរសំ | មានការកើតរួមគ្នាជាមួយនឹងចិត្ត ជាកិច្ច |
| ៣- ឯកាលម្ពណបច្ចុប្បដ្ឋានំ | មានអារម្មណ៍តែមួយជាមួយនឹងចិត្ត ជាអាការប្រាកដ |
| ៤- ចិត្តុប្បាទបទដ្ឋានំ | មានការកើតឡើងនៃចិត្ត ជាហេតុជិត។ |

# ចេតសិក ៥២

## អញ្ញសមានា ១៣

១- ផស្សៈ
២- វេទនា
៣- សញ្ញា
៤- ចេតនា
៥- ឯកគ្គតា
៦- ជីវិតិន្ទ្រិយ
៧- មនសិការៈ
៨- វិតក្កៈ
៩- វិចារៈ
១០- អធិមោក្ខៈ
១១- វីរិយៈ
១២- បីតិ
១៣- ឆន្ទៈ

## អកុសលចេតសិក ១៤

១- មោហៈ
២- អហិរិកៈ
៣- អនោត្តប្បៈ
៤- ឧទ្ធច្ចៈ
៥- លោភៈ
៦- ទិដ្ឋិ
៧- មានៈ
៨- ទោសៈ
៩- ឥស្សា
១០- មច្ឆរិយៈ
១១- កុក្កុច្ចៈ
១២- ថីនៈ
១៣- មិទ្ធៈ
១៤- វិចិកិច្ឆា

## សោភណចេតសិក ២៥

១- សទ្ធា
២- សតិ
៣- ហិរិ
៤- ឱត្តប្បៈ
៥- អលោភៈ
៦- អទោសៈ
៧- តត្រមជ្ឈត្តតា
៨- កាយបស្សទ្ធិ
៩- ចិត្តបស្សទ្ធិ
១០- កាយលហុតា
១១- ចិត្តលហុតា
១២- កាយមុទុតា
១៣- ចិត្តមុទុតា
១៤- កាយកម្មញ្ញតា
១៥- ចិត្តកម្មញ្ញតា
១៦- កាយបាគុញ្ញតា
១៧- ចិត្តបាគុញ្ញតា
១៨- កាយុជុកតា
១៩- ចិត្តុជុកតា
២០- សម្មាវាចា
២១- សម្មាកម្មន្តៈ
២២- សម្មាអាជីវៈ
២៣- ករុណា
២៤- មុទិតា
២៥- បញ្ញា